NDIS Quality and Safeguards Commission

NDIS Workforce Capability Framework
Your guide to attitudes, skills and knowledge for NDIS work

# ក្របខ័ណ្ឌសមត្ថភាពកម្លាំងពលកម្ម NDIS៖ ធនធានការជ្រើសរើសបុគ្គលិក និងការសម្រិតសម្រាំងបុគ្គលិក

Khmer | ភាសាខ្មែរ

ក្របខ័ណ្ឌសមត្ថភាពកម្លាំងពលកម្ម NDIS (ក្របខ័ណ្ឌ) ពណ៌នាអំពីអាកប្បកិរិយា ជំនាញ និងចំណេះដឹងដែលត្រូវបានរំពឹងទុកពីបុគ្គលិកទាំងអស់ដែលបានទទួលមូលនិធិនៅក្រោម NDIS។ វាផ្តល់នូវឧទាហរណ៍ច្បាស់លាស់ និងជាក់ស្តែងមួយចំនួន ហើយបង្កើតជាភាសារួមអំពី 'អ្វីដែលមើលទៅល្អ' សម្រាប់អ្នកចូលរួមទាំងឡាយដែលកំពុងទទួលសេវា និងការគាំទ្រពី NDIS។

ធនធានសម្រាប់ការជ្រើសរើសបុគ្គលិក និងការសម្រិតសម្រាំងបុគ្គលិក ផ្តល់ដំបូន្មានអំពីរបៀបដំណើរការជ្រើសរើសបុគ្គលិកដោយប្រើក្របខ័ណ្ឌនេះ។ ការណែនាំជាជំហានៗ និងទម្រង់គំរូនានាដែលអាចទាញយកបាន មានផ្តល់ជូនជាពីរកំណែ គឺមួយសម្រាប់អ្នកផ្តល់សេវា ហើយមួយទៀតសម្រាប់អ្នកចូលរួមនានាដែលជួលបុគ្គលិកផ្ទាល់ខ្លួនរបស់ពួកគេ។

*ការមានសិទ្ធិចូលប្រើប្រាស់ទម្រង់គំរូទាំងនេះ និងការណែនាំអំពី 'របៀប' សម្រាប់ជំហាននីមួយៗនៃដំណើរការជ្រើសរើសបុគ្គលិក គឺមានតម្លៃសម្រាប់អ្នកផ្តល់សេវា ឬអ្នកចូលរួមទាំងឡាយដែលជួលបុគ្គលិកគាំទ្រ។ ទម្រង់គំរូ និងឧទាហរណ៍នានា ពិតជាបង្ហាញពីរបៀបជ្រើសរើសបុគ្គលិកសម្រាប់សមត្ថភាពនានា។*

## អ្វីខ្លះដែលនឹងរំពឹងទុក

សៀវភៅមគ្គុទ្ទេសក៍នេះគាំទ្រអ្នកផ្តល់សេវា NDIS និងអ្នកចូលរួមទាំឡាយដែលជ្រើសរើសបុគ្គលិក និងការសម្រិតសម្រាំងបុគ្គលិកដោយមានក្របខ័ណ្ឌនេះនៅក្នុងចិត្ត។

- **លៃតម្រូវ៖** លៃតម្រូវដំណើរការជ្រើសរើសបុគ្គលិករបស់អ្នកជាមួយក្របខ័ណ្ឌនេះ។
- **រុករក៖** ចូលប្រើគន្លឹះនានា និងការណែនាំជាក់ស្តែងសម្រាប់ជំហាននីមួយៗនៃដំណើរការនេះ។
- **ចូលប្រើ៖** ទាញយកទម្រង់គំរូនានាដែលអាចកែសម្រួលបាន ដើម្បីគាំទ្រដល់ដំណើរការជ្រើសរើសបុគ្គលិក។

NDIS Quality and Safeguards Commission

NDIS Workforce Capability Framework

Your guide to attitudes, skills and knowledge for NDIS work

## សៀវភៅមគ្គុទេសក៍នៅក្នុងការអនុវត្ត៖

**អ្នកចូលរួម៖** Kyle ជួលបុគ្គលិកគាំទ្រផ្ទាល់ខ្លួនរបស់គាត់ជាមួយនឹងកញ្ចប់ NDIS ដែលគ្រប់គ្រងដោយខ្លួនឯង។ គាត់បានប្រើប្រាស់ឧបករណ៍បង្កើតការពណ៌នាមុខតំណែង ដើម្បីកំណត់ការរំពឹងទុករបស់គាត់ និងព័ត៌មានសំខាន់ៗផ្សេងទៀត មុនពេលបន្តទៅមុខទៀតក្នុងការជ្រើសរើសបុគ្គលិក ដូច្នេះគាត់មានភាពច្បាស់លាស់អំពីសមត្ថភាពដែលគាត់កំពុងស្វែងរក ប៉ុន្តែមិនប្រាកដថាត្រូវចាត់វិធានការបែបណាដើម្បីជ្រើសរើសបុគ្គលិក ឬរបៀបសម្ភាសន៍ និងជ្រើសរើសបុគ្គលិកដែលត្រឹមត្រូវ។

គាត់ប្រើប្រាស់ **ធនធានសម្រាប់ការជ្រើសរើស និងការសម្រិតសម្រាំងបុគ្គលិក**ដើម្បីឈានចូលដំណើរការជ្រើសរើសបុគ្គលិក បង្កើតសំណួរសម្ភាសន៍ និងស្វែងរកបុគ្គលិកដែលសក្តិសមនឹងតម្រូវការរបស់គាត់។ ការនេះជួយឱ្យគាត់គិតបានហ្មត់ចត់លើបញ្ហាមួយចំនួនដែលគាត់មិនបានពិចារណាពីមុនមក។ ឧទាហរណ៍ គាត់ចាត់ចែងកិច្ចសម្ភាសន៍អ្នកដាក់ពាក្យសុំមួយចំនួននៅហាងកាហ្វេមួយ ជាជាងនៅផ្ទះរបស់គាត់ ហើយស្នើសុំឱ្យបងប្រុសរបស់គាត់អង្គុយជាមួយគាត់ ដើម្បីជួយគាត់ក្នុងការតាមដានចម្លើយនានា និងផ្តល់ទស្សនៈទីពីរដល់គាត់ចំពោះអ្នកដាក់ពាក្យសុំ។

**អ្នកចូលរួម៖** Jess ចូលរួមជាមួយបុគ្គលិករបស់នាងតាមរយៈអ្នកផ្តល់សេវា ប៉ុន្តែមានចំណាប់អារម្មណ៍យ៉ាងខ្លាំងចំពោះអ្នកដែលត្រូវបានជ្រើសរើសឱ្យចូលរួមក្នុងក្រុមគាំទ្ររបស់នាង។ អ្នកផ្តល់សេវារបស់នាងលើកទឹកចិត្តនាងឱ្យក្លាយជាផ្នែកនៃដំណើរការ ហើយនាងប្រើប្រាស់ **ធនធានសម្រាប់ការជ្រើសរើសបុគ្គលិក និងការសម្រិតសម្រាំងបុគ្គលិក** ដើម្បីទទួលបានការយល់ដឹងអំពីជំហាននីមួយៗ ដូច្នេះនាងអាចសម្រេចចិត្តថាតើនាងចង់ចូលរួមនៅពេលណា និងរបៀបដែលនាងចង់ចូលរួម។

នាងយល់ស្របជាមួយអ្នកផ្តល់សេវាអំពីលក្ខណៈវិនិច្ឆ័យដែលពួកគេនឹងប្រើប្រាស់ដើម្បីជ្រើសរើសពាក្យសុំ និងដើម្បីអង្គុយនៅក្នុងក្រុមសម្ភាសន៍ និងដំណើរការជ្រើសរើសរួមគ្នាជាមួយធនធានមនុស្ស (HR) និងអ្នកគ្រប់គ្រងសេវាកម្មពីអ្នកផ្តល់សេវារបស់នាង។

**អ្នកផ្តល់សេវា៖** NDIS Care មានផែនការមួយចំនួនដើម្បីផ្តល់ការគាំទ្រឯកទេសថ្មី ហើយចង់ជ្រើសរើសបុគ្គលិកដែលល្អបំផុតសម្រាប់ការងារ ប៉ុន្តែពួកគេមិនមានដំណើរការ ឬទម្រង់គំរូបច្ចុប្បន្នទេ។

ដោយប្រើសៀវភៅមគ្គុទ្ទេសក៍នេះ និងទម្រង់គំរូនានានោះ NDIS Care បង្កើតដំណើរការជ្រើសរើសបុគ្គលិកដែលត្រូវបានរចនាឡើងដើម្បីវាយតម្លៃអ្នកដាក់ពាក្យសុំទល់នឹងនឹងសមត្ថភាពឯកទេសចាំបាច់ ក៏ដូចជាសមត្ថភាពស្នូល និងតម្រូវការផ្សេងទៀត។ ផ្អែកលើភាពជោគជ័យនៃដំណើរការនេះ, NDIS Care សម្រេចចិត្តប្រើប្រាស់សៀវភៅមគ្គុទ្ទេសក៍នេះ ដើម្បីគាំទ្រដល់រាល់តម្រូវការទាំងអស់ក្នុងការជ្រើសរើសបុគ្គលិកនាពេលអនាគតរបស់ពួកគេ។

NDIS Care ក៏បានប្រើប្រាស់ **ឧបករណ៍គ្រប់គ្រង និងផែនការកម្លាំងពលកម្ម** ព្រមទាំង **ឧបករណ៍បង្កើតការពណ៌នាអំពីមុខតំណែង** ផងដែរដើម្បីបង្កើតនូវលក្ខខណ្ឌតម្រូវច្បាស់លាស់នៅមុនពេលបន្តទៅមុខទៀតនៅក្នុងការជ្រើសរើសបុគ្គលិក។

## ការចូលប្រើប្រាស់ និងការប្រើប្រាស់សៀវភៅមគ្គុទេសក៍

ធនធានសម្រាប់ការជ្រើសរើសបុគ្គលិក និងការសម្រិតសម្រាំងបុគ្គលិកមាននៅតាមអនឡាញ និងនៅក្រៅបណ្តាញ ដោយមានធនធាន និងទម្រង់គំរូនានាដែលអាចទាញយកបាន។ សៀវភៅមគ្គុទ្ទេសក៍នេះអាចត្រូវបានប្រើប្រាស់ជាធនធាននៅពេលអ្នកបន្តមានវឌ្ឍនភាពនៅទូទាំងដំណាក់កាលនៃការរើសបុគ្គលិក។ អ្នកអាចទាញយកធនធានទាំងអស់ រួមទាំងទម្រង់គំរូនានាជាឯកសារតែមួយ ឬជាឯកសារដោយឡែកៗ។

**ចូលប្រើសៀវភៅមគ្គុទ្ទេសក៍៖** ធនធានសម្រាប់ការជ្រើសរើសបុគ្គលិក និងការសម្រិតសម្រាំងបុគ្គលិក | សមត្ថភាពកម្លាំងពលកម្ម NDIS ( ndiscommission.gov.au )

សម្រាប់ព័ត៌មានបន្ថែមអំពីក្របខ័ណ្ឌ ឬការអនុវត្តរបស់សៀវភៅមគ្គុទ្ទេសក៍នេះ សូមចូលមើលគេហទំព័រ៖ https://workforcecapability.ndiscommission.gov.au/។

**ទំនាក់ទំនង៖** contactcentre@ndiscommission.gov.au ឬ 1800 035 554។